ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*** ***

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៨ សរ

# សារាចរ

## ស្តីពីការគោរពសណ្តាប់ធ្នាប់ របៀបរៀបរយ នៅពេលប្រលង

កន្លងមក ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង មធ្យមសិក្សាបឋមភូមិ បានទទួលលទ្ធផលល្អមួយគួរគាប់ហើយ បើប្រៀបធៀបទៅនឹងលទ្ធភាពដែលយើងមាន និង សភាពការណ៍ជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជាយើង ។ ប៉ុន្តែយើងនៅមានចំនុចសេសសល់ខ្លះៗ ដែលចាំបាច់ត្រូវកែលំអដូចជា :

- ការបង្កភាពអនាធិបតេយ្យ រំខានដល់ប្រក្រតីភាពនៃការប្រលង ។
- ការថតចំលងចំលើយវិញ្ញាសា លក់តគ្រឹកតគ្រេងជុំវិញមណ្ឌលប្រលង ។
- បាតុភាពបោះ គប់សំណៅចំលើយនៃវិញ្ញាសាចូលបន្ទប់ប្រលង ។
- ការរត់សំរុកចូលក្នុងមណ្ឌលប្រលង បន្ទប់ប្រលងដើម្បីយកសំនៅចំលើយវិញ្ញាសាទៅអោយបេក្ខជន ។
- ការគំរាមកំហែងមេប្រយោគ ។
- បើកតៀមលក់ដូរ នំចំណី ជុំវិញមណ្ឌលប្រលងដែលជាជំរកសំរាប់ជនខិលខូច បង្កភាពអនាធិបតេយ្យ ។
- យកភារកិច្ចការពារសុវត្ថិភាពមណ្ឌលប្រលងទៅជាភ្នាក់ងាររត់សំណៅចំលើយវិញ្ញាសាចូលមណ្ឌលប្រលង បន្ទប់ប្រលង រឺ ការពារជនខិលខូចទៅវិញ ។

អាស្រ័យហេតុនេះ ដើម្បីអោយការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង មធ្យមសិក្សាបឋមភូមិនៅដំណាច់ឆ្នាំសិក្សានេះ ប្រព្រឹត្តទៅក្នុងភាពប្រក្រតី មានសណ្តាប់ធ្នាប់រៀបរយល្អ ធានាបាននូវភាពយុត្តិធម៌ជូនបេក្ខជន និង មាតាបិតា ឬ អាណាព្យាបាលរបស់បេក្ខជន រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ÷

១. គ្រប់ក្រសួង និង គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងផ្សព្វផ្សាយ និង អប់រំអោយបានទូលាយជូនមន្ត្រីរាជការបុគ្គលិក កម្មករ នៅទូទាំងក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង អោយយល់ពីលក្ខណការណ៍នៃការប្រលងដែលផ្សព្វផ្សាយ ដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីចៀសវាងនូវប្រការដែលផ្ទុយនឹងបទបញ្ញត្តិនៃការប្រលង រឺ ធ្វើអោយខូចសណ្តាប់ធ្នាប់របៀបរៀបរយ បង្កអោយមានភាពអនាធិបតេយ្យ ក្នុងពេលប្រលង ។ សូមណែនាំអប់រំ បងប្អូន កូនចៅអោយមានជំនឿទុកចិត្តលើសមត្ថភាពរបស់ខ្លួន និង លើរាជរដ្ឋាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ក្នុងការធ្វើអោយការងារប្រលងមានលក្ខណៈយុត្តិធម៌ ជូនមាតាបិតា អាណាព្យាបាលសិស្សានុសិស្សទាំងអស់ ។ សូមបញ្ឈប់ដាច់ខាតអន្តរាគមន៍ ដោយសូកប៉ាន់មេប្រយោគ ដោយទិញចំលើយវិញ្ញាសា ហើយជួលកំលាំងនាំសំណៅចូលទៅក្នុងបន្ទប់ប្រលង និង បង្កអោយកូនចៅលាក់អាវុធ ឬ ជាតិផ្ទុះសំរាប់គំរាមកំហែងមេប្រយោគ ឬ បង្កប់វិទ្យុទាក់ទងសំរាប់បញ្ជូនខ្លឹមសារប្រធានវិញ្ញាសាចេញក្រៅដើម្បីអោយកូនចៅប្រលងជាប់ ដែលជាលក្ខណៈផ្ទុយនឹងភាពយុត្តិធម៌ ។

២. ក្រសួងមហាផ្ទៃ ត្រូវណែនាំដល់សាលាខេត្ត-ក្រុង អោយស្នងការនគរបាល រៀបចំកំលាំងការពារ សុខសុវត្ថិភាព និង សណ្តាប់ធ្នាប់ របៀបរៀបរយ តាមមណ្ឌលប្រលងនីមួយៗ ក្នុងខេត្ត-ក្រុង របស់ខ្លួន អោយបានល្អប្រសើរ ។

៣. ចំពោះលោកគ្រូ-អ្នកគ្រូជាមេប្រយោគ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការងារប្រលង និង កងនគរបាល ដែលមានភារកិច្ចចូលរួមរក្សា ការពារសណ្តាប់ធ្នាប់ របៀបរៀបរយ នៅតាមមណ្ឌលប្រលង ត្រូវ អនុវត្តអោយបានតាមភារកិច្ចរបស់ខ្លួន ក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ធ្វើអោយការប្រលងប្រព្រឹត្តទៅក្នុងភាព ប្រក្រតី យុត្តិធម៌ ចៀសវាងដាច់ខាតនូវការប្រព្រឹត្តអ្វីដែលជាហេតុបណ្តាលអោយខូចវិន័យ និង សណ្តាប់ធ្នាប់នៃ ការប្រលង ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្តៅបំផុត ថាក្រសួង សាលាខេត្ត-ក្រុង ទាំងអស់នឹងយកអស់សមត្ថភាព ពុះពារគ្រប់ការលំបាក លើកកំពស់ឆន្ទៈ អនុវត្តតាមខ្លឹមសារ សារាចរណែនាំនេះអោយមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី...១៩...ខែ [illegible] ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចំលងជូន</u> :

- ក្រសួងអប់រំ យុវជន និង កីឡា
  «ដើម្បីទុកជាឯកសារ»
- គ្រប់ក្រសួង សាលាខេត្ត-ក្រុង
  «ដើម្បីអនុវត្ត»
- កាលប្បវត្តិ-ឯកសារ

លេខៈ.........០២...........អយក.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ២០១៣

**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អគ្គនាយក**

**ជោង បូរ៉ាន់**